# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 14-Jun-2012, 14:04
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់លោក អៀង សារី សុំឲ្យមានការកិច្ចប្រជុំរៀបចំសវនាការផ្លូវការមួយ ដើម្បីពិភាក្សាពីលទ្ធភាពនៃការចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយ** (S-Drive)

---

**ដាក់ដោយ:**

**សហមេធាវី:**

អាង ឧត្តម
Michael G. KARNAVAS

**អង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម **និល ណុន** ជាប្រធាន

ចៅក្រម **យូរ ឧត្តរា**

ចៅក្រម **យ៉ា សុខន**

ចៅក្រម **Silvia CARTWRIGHT**

ចៅក្រម **Jean-Marc LAVERGNE**

ចៅក្រមបម្រុង **ធូ មណី**

ចៅក្រមបម្រុង **Claudia FENZ**

**សហព្រះរាជអាជ្ញា:**

ជា លាង
Andrew CAYLEY

**ក្រុមមេធាវីការពារក្ដីទាំងអស់**
**ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីរបស់ខ្លួន (“មេធាវីការពារក្តី”) ដោយអនុលោមតាមវិធាន ៧៩ (៧)[១] សូមស្នើទៅអង្គជំនុំជម្រះសាលាដំបូងសុំឲ្យកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការជាផ្លូវការមួយ ក្នុងគោលបំណងពិភាក្សា ដើម្បីអោយមានជាកំណត់ត្រា ស្តីពីលទ្ធភាពនៃការដាក់អោយចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយ (S-Drive)។ មេធាវីការពារក្តីក៏បានបន្តស្នើទៅអង្គជំនុំជម្រះ សាលាដំបូងសុំឲ្យបង្គាប់ទៅអ្នកតំណាងការិយាល័យរដ្ឋបាល រួមទាំងមន្ត្រីពាក់ព័ន្ធដទៃទៀតឲ្យមកឆ្លើយបំភ្លឺនៅក្នុងកិច្ចប្រជុំនេះ[២]។ សំណើនេះមានការចាំបាច់ដោយហេតុថាការិយាល័យរដ្ឋបាលមិនបានយកចិត្តទុកដាក់ចំពោះសំណើក្នុងការដាក់ភាគីឲ្យចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយ(S-Drive) ឬមិនទាន់ផ្តល់នូវការពន្យល់ណាមួយពីមូលហេតុដែលមិនអាចធ្វើបែបនេះបាន។ ដោយសារការចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយនឹងជួយដល់ភាគីយ៉ាងច្រើន ក្នុងការបំពេញការងាររបស់ខ្លួន និងបង្កើននូវផលិតភាពរបស់ខ្លួន (ហើយទោះបីមេធាវីការពារក្តីអះអាងថា ខ្លួនពុំមានជំនាញផ្នែកបច្ចេកវិទ្យាអ៊ីនធឺណិតក៏ដោយ) ក៏ខ្លួនយល់ឃើញថា ការអនុញ្ញាតឲ្យចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួម ពីចម្ងាយពិតជាបង្កើនបាននូវសុវត្ថិភាពផ្នែកព័ត៌មានដែរ។ នេះដោយសារ នាពេលបច្ចុប្បន្ននេះភាគីតម្រូវឲ្យរក្សាទុកព័ត៌មាន (save) ទុកក្នុងបន្ទះផ្ទុកទិន្ន័យខ្នាតតូច (usb flash drives) ឬ បន្ទះផ្ទុកទិន្ន័យខ្នាតធំ (external hard drives) ដើម្បីបន្ត

---

[១] វិធាន ៧៩(៧) នៃវិធានផ្ទៃក្នុង អ.វ.ត.ក (“វិធាន”) ចែងថា៖ “ដើម្បីសម្របសម្រួលដល់ការប្រព្រឹត្តិទៅនៃកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស អង្គជំនុំជម្រះសាលាដំបូង អាចពិគ្រោះយោបល់ជាមួយភាគីទាំងឡាយ ដោយធ្វើការប្រជុំរៀបចំសវនាការ ប្រសិនបើយល់ឃើញថាចាំបាច់”។ វាទំនងជាលេចឡើងថា កិច្ចប្រជុំដែលបានលើកឡើងក្នុងវិធាន ៧៩ (៧) គឺត្រូវធ្វើឡើងមុនចាំបាច់សវនាការ ក៏ប៉ុន្តែវិធាននេះមិនបានហាមឃាត់មិនឲ្យអង្គជំនុំជម្រះសាលាដំបូងរៀបចំកិច្ចប្រជុំរៀបចំសវនាការនៅក្នុងដំណាក់កាលដទៃៗនោះទេ។

[២] ចំណុចនេះត្រូវបានអនុញ្ញាតដោយវិធាន ៧៩(៨) ដែលចែងថា៖ “អង្គជំនុំជម្រះអាច ... អញ្ជើញអ្នកតំណាងការិយាល័យរដ្ឋបាល ដែលក្នុងនោះរួមទាំងតំណាងពីផ្នែកផ្សេងៗ ឬ អង្គភាពផ្សេងៗរបស់តុលាការឲ្យចូលរួមផងដែរ”។ វិធាន ៩(១) (ស្តីពីមុខងាររបស់ការិយាល័យរដ្ឋបាល) ផ្តល់ការគាំទ្របន្ថែមទៀត។ វិធាននេះចែងថា៖ “ការិយាល័យរដ្ឋបាលត្រូវជួយគាំទ្រលើការបំពេញការងាររបស់អង្គជំនុំជម្រះ ... និងត្រូវទទួលខុសត្រូវចំពោះកិច្ចការរដ្ឋបាល និងការផ្តល់សេវាកម្មរបស់ស្ថាប័នទាំងនោះ។ ក្នុងករណីនេះ មន្ត្រីតុលាការនៃការិយាល័យខាងលើ អាចលើកជាសំណើទៅកាន់ការិយាល័យរដ្ឋបាល តាមរយៈគណៈកម្មាធិការរដ្ឋបាលតុលាការ ដោយរួមបញ្ចូលទាំងវិធានការខាងវិន័យចំពោះបុគ្គលិក ដែលស្ថិតនៅក្រោមអំណាចរបស់ខ្លួន តាមការចាំបាច់”។

[៣]មេធាវីការពារក្តីបានផ្ញើរនូវឧបសម្ព័ន្ធស្តីពីអំឡុងពេលនៃកាលបរិច្ឆេទមួយដែលបានដាក់ចេញនូវជំហ៊ាននានារបស់មេធាវីការពារក្តី និង ភាគីដ៏ទៃទៀតដែលឆ្លុះបញ្ចាំងទៅលើបញ្ហានេះ។

[៦] ជាពិសេសដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយថា ការចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយមានសារៈសំខាន់ខ្លាំងណាស់ ដោយហេតុថាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនរស់នៅ និងធ្វើការនៅបរទេស។

ធ្វើការតទៅទៀត នៅពេលខ្លួនចាកចេញពីការិយាល័យ។ ការប្រើប្រាស់យ៉ាងទូលំទូលាយនូវឧបករណ៍ទាំងនេះនឹងបង្កើននូវហានិភ័យដោយការចម្លងមេរោគ (virus) ដល់កុំព្យូទ័រ ហើយក៏អាចនាំឲ្យលេចឡើងនូវបញ្ហាដែលថា ឧបករណ៍ទាំងនេះដែលអាចមានផ្ទុកនូវព័ត៌មានរសើបនានានោះ អាចនឹងត្រូវបាត់បង់ ឬត្រូវគេលួចបាត់ផងក៏មាន។ ការចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយជួយសន្សំពេលវេលា និងប្រាក់កាសបានច្រើនណាស់។ វានឹងជួយកាត់បន្ថយនូវការធ្វើដំណើរតាមរថយន្តទាំងទៅទាំងមក រយៈពេលជាងពីរម៉ោងពីក្រុងភ្នំពេញមកកាន់ អ.វ.ត.ក ដើម្បីបំពេញការងារដែលគេអាចធ្វើបានពីចម្ងាយ។ ជាពិសេស នាពេលនេះវាមានសារៈសំខាន់ ដោយសារថា សវនាការបានចាប់ផ្តើមហើយ ហើយភាគីមានពេលទំនេរតែពេលយប់ និងថ្ងៃចុងសប្តាហ៍ ដើម្បីរៀបចំសំណុំឯកសារសម្រាប់សវនាការ និងបំពេញការងារពាក់ព័ន្ធដទៃទៀត។ វាជួយសន្សំសំចៃថវិកា ដោយអនុញ្ញាតឲ្យបុគ្គលិក និងទីប្រឹក្សារបស់ភាគី បំពេញការងាររបស់ខ្លួនពីចម្ងាយបាន ដោយពុំចាំបាច់ជិះយន្តហោះធ្វើដំណើរមកកាន់ក្រុងភ្នំពេញមក អ.វ.ត.ក ញឹកញាប់ដូចសព្វថ្ងៃនេះទេ។

**អាស្រ័យហេតុនេះ** សម្រាប់សំអាងហេតុដែលបានលើកឡើងខាងលើ មេធាវីការពារក្តីសូមស្នើអង្គជំនុំជម្រះសាលាដំបូងសុំឲ្យកំណត់កាលបរិច្ឆេទនៃការរៀបចំកិច្ចប្រជុំរៀបចំសវនាការមួយជាផ្លូវការ ឲ្យបានកាន់តែឆាប់កាន់តែប្រសើរ និងសុំឲ្យកោះហៅអ្នកតំណាងការិយាល័យរដ្ឋបាល រួមទាំងមន្ត្រីដទៃទៀតដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាពាក់ព័ន្ធមកឆ្លើយបំភ្លឺ។

សូមលោក លោកស្រីចៅក្រម មេត្តាទទួលយកសំណើនេះដោយគោរព។

អាង ឧត្តម     Michael G. KARNAVAS

សហមេធាវីការពារក្តីលោក អៀង សារី

ចុះហត្ថលេខានៅរាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១៤ ខែ មិថុនា ឆ្នាំ ២០១២**